**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០៧៦/២១ សរណ

ថ្ងៃ ចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការក្រើនរំលឹកដល់ប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងមាតាបិតា-អាណាព្យាបាល របស់កុមារ និងយុវជនមានអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នៅក្នុងរាជធានីភ្នំពេញ ដើម្បីអញ្ជើញមកទទួលចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា

**រដ្ឋបាលរាជធានីភ្នំពេញ** សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ ឱ្យបានជ្រាបថា យោងតាមសេចក្តីណែនាំលេខ **០៦ សណន** ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពង្រឹងការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ **"ជុំទី១"** និងដោយទទួលបានការប្រគល់ភារកិច្ចពីគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) **អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងរាជធានីភ្នំពេញ** បានចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងកុមារ-យុវជនមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ សម្រេចបានស្ទើរតែ **១00%** នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ **ដែលសមិទ្ធផលនេះ** ពិតជាបានបង្ហាញឱ្យឃើញកាន់តែច្បាស់ពីការកសាងខឿនសុខុមាលភាពយ៉ាងរឹងមាំ និងការការពារអាយុជីវិតប្រជាជនប្រឆាំងនឹងជំងឺរាតត្បាតសកលកូវីដ-១៩ ប្រកបដោយភាពប្រាកដនិយម និងទស្សនវិស័យដឹកនាំដ៏ឧត្តុង្គឧត្តមបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។

**ក្នុងន័យនេះ** ដើម្បីជំរុញការអនុវត្ត **យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ "ជុំទី១"** និងការអនុវត្តបន្តនូវ**គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ "ដូសជំរុញ"** ឱ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរ សំដៅបង្កើតឱ្យបាន **"ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ"** ទប់ទល់នឹងជំងឺរាតត្បាតសកលកូវីដ-១៩ ជាពិសេសមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) ក៏ដូចជាដើម្បីត្រៀមលក្ខណៈសម្រាប់ការរស់នៅជាមួយជំងឺកូវីដ-១៩ តាមបែបគន្លងប្រក្រតីភាពថ្មី ឈានឆ្ពោះទៅរកការបើកដំណើរការឡើងវិញលើគ្រប់វិស័យ នាពេលឆាប់ៗខាងមុខនេះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមធ្វើការក្រើនរំលឹក ដូចខាងក្រោម៖

១. ចំពោះបងប្អូនប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលបានទទួលវ៉ាក់សាំងដូសទី១ រួចរាល់ហើយ សូមអញ្ជើញមកទទួលវ៉ាក់សាំងដូសទី២ **រៀងរាល់ម៉ោង ៨:00នាទីព្រឹក ដល់ម៉ោង ៥:00នាទីរសៀល តាមកាលបរិច្ឆេទដែលបានកំណត់ ក្នុងបណ្ណចាក់វ៉ាក់សាំង នៅតាមទីតាំងដែលខ្លួនបានអញ្ជើញមកទទួលវ៉ាក់សាំងដូសទី១ នាពេលកន្លងមក។**

២. ចំពោះកុមារ និងយុវជនមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលបានទទួលវ៉ាក់សាំងដូសទី១ រួចរាល់ហើយ សូមមាតាបិតា ឬ អាណាព្យាបាល នាំយកបុត្រធីតារបស់លោកអ្នក ទៅទទួលវ៉ាក់សាំងដូសទី២ **រៀងរាល់ម៉ោង ៨:00នាទីព្រឹក ដល់ម៉ោង ៥:00នាទីរសៀល តាមកាលបរិច្ឆេទដែលបានកំណត់ ក្នុងបណ្ណចាក់វ៉ាក់សាំង នៅតាមទីតាំងដែលបានអញ្ជើញមកទទួលវ៉ាក់សាំងដូសទី១ នាពេលកន្លងមក។**



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៣. ចំពោះបងប្អូនប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងកុមារ-យុវជនមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលមិនទាន់បានទទួលវ៉ាក់សាំងដូសទី១ សូមបងប្អូនប្រជាពលរដ្ឋ និងមាតាបិតា ឬ អាណាព្យាបាល **មេត្តារួសរាន់អញ្ជើញមក ឬ នាំយកបុត្រធីតាលោកអ្នក មកទទួលវ៉ាក់សាំងរៀងរាល់ម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ៥:០០នាទីរសៀល នៅតាមទីតាំងមន្ទីរពេទ្យបង្អែក ចំនួន ០៨ទីតាំង រួមមាន ៖**

| ល.រ | ឈ្មោះមន្ទីរពេទ្យបង្អែក | អាសយដ្ឋាន |
|---|---|---|
| ១ | មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ | ផ្លូវលេខ ១៣៤ កែងផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា |
| ២ | មន្ទីរពេទ្យបង្អែកចតុមុខ | ផ្លូវជាតិលេខ ៥ ភូមិ១៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ |
| ៣ | មន្ទីរពេទ្យបង្អែកដង្កោ | ផ្លូវលេខ ២១៧ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ |
| ៤ | មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិនសែនសុខ | ផ្លូវសែនសុខ៥ ភូមិសែនសុខទី៥ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ |
| ៥ | មន្ទីរពេទ្យបង្អែកច្បារអំពៅ | ផ្លូវលេខ៣៦១ កែងផ្លូវលេខ ៦៣៨ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ |
| ៦ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | ផ្លូវលេខ ៥៦K ភូមិតាងួន២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ |
| ៧ | មន្ទីរពេទ្យបង្អែកព្រែកព្នៅ | ភូមិពោធិ៍មង្គល សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ |
| ៨ | មន្ទីរពេទ្យបង្អែកសម្តេចឪ-សម្តេចម៉ែ | ផ្លូវជាតិលេខ ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ |

៤. **ដោយឡែក** ចំពោះបងប្អូនប្រជាពលរដ្ឋដែលជាសហព័ទ្ធ (ស្វាមី ឬ ភរិយា) របស់មន្ត្រីបម្រើសេវាសាធារណៈ ជួរមុខនៃរដ្ឋបាលរាជធានីភ្នំពេញ និងប្រជាពលរដ្ឋដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ ដែលបានចាក់វ៉ាក់សាំងកូវីសែល (COVISHIELDTM) ដូសទី១ និងដូសទី២ រួចរាល់ នៅរាជធានីភ្នំពេញ សូមអញ្ជើញរួសរាន់ទៅទទួលវ៉ាក់សាំងអាស្ត្រាហ្សេនីកា (AstraZeneca) ដូសទី៣ ឬ ដូសជំរុញ ឱ្យបានទាន់ពេលវេលា ទៅតាមកម្មវិធី និងទីកន្លែងដែលបានកំណត់ជូន ដូចមានខ្លឹមសារនៅក្នុងសេចក្តីជូនដំណឹងលេខ **០៦៩/២១ សជណ** ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ។

ទន្ទឹមនឹងនេះ មុនពេលអញ្ជើញទៅទទួលវ៉ាក់សាំង ចំពោះប្រជាពលរដ្ឋទាំងឡាយណា ដែលមានបញ្ហាសុខភាព ដូចជា ក្តៅខ្លួន ក្អក-កណ្តាស់ ផ្តាសាយ ពិបាកដកដង្ហើម ឬ រោគសញ្ញាផ្សេងទៀត សូមប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយខ្លួនឯង ដើម្បីបញ្ជាក់ពីស្ថានភាពសុខភាព និងលទ្ធផលតេស្តអវិជ្ជមាន ស្របតាមគោលការណ៍ណែនាំប្រតិបត្តិរបស់ក្រសួងសុខាភិបាល ឬ អញ្ជើញទៅយកសំណាកវិភាគរកមេរោគកូវីដ-១៩ នៅតាមទីតាំងយកសំណាករបស់រដ្ឋ ជាមុនសិន ចៀសវាងប៉ះពាល់ដល់ក្រុមគ្រូពេទ្យ និងប្រជាពលរដ្ឋដទៃទៀត។ ជាមួយគ្នានេះ ក្នុងអំឡុងពេលអញ្ជើញមកទទួលវ៉ាក់សាំង សូមបងប្អូនប្រជាពលរដ្ឋចូលរួមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល និងត្រូវប្រកាន់ខ្ជាប់នូវវិធានការ **"៣ ការពារ និង ៣ កុំ"** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមបងប្អូនប្រជាពលរដ្ឋ សាធារណជន និងមាតាបិតា-អាណាព្យាបាល ជាពិសេសប្រជាពលរដ្ឋដែលមិនទាន់ទទួលបានវ៉ាក់សាំង ក្នុងមូលដ្ឋានរាជធានីភ្នំពេញ មេត្តាជ្រាបជាព័ត៌មាន និងរួសរាន់អញ្ជើញមកទទួលវ៉ាក់សាំងដោយឥតគិតថ្លៃ ឱ្យបានទាន់ពេលវេលា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសុខាភិបាល
-គ.វ.ក-១៩
*"ដើម្បីជូនជ្រាបជាព័ត៌មាន!"*
-រដ្ឋបាលខណ្ឌទាំង១៤
-មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ
*"ដើម្បីមុខការ!"*
-គ្រប់ប្រព័ន្ធឃោសនា
*"ដើម្បីផ្សព្វផ្សាយ!"*
-ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh